# មាតាបិតាក៏រាប់ផងដែរ

## ការជួយកូនរបស់លោកអ្នកនៅក្នុង – ការគិតលេខដោយប្រើគំនិតប្រាជ្ញា

ការគិតលេខភាគច្រើនដែលយើងធ្វើរៀងរាល់ថ្ងៃ គឺយើងធ្វើចេញពីគំនិតប្រាជ្ញារបស់យើង។ ចំពោះការគិតលេខខ្លះ យើងហាក់បីដូចជាចង់ឈោងចាប់យកក្រដាស និងខ្មៅដៃ ឬម៉ាស៊ីនគិតលេខ។ ក៏ប៉ុន្តែពេលណាយើងលេងល្បែងគប់ព្រួញលើបន្ទះក្តារ ឬលេងបៀរ ឬមើលក្រុមប្រកួតកីឡាយើងពឹងផ្អែកទៅលើការគិតលេខយ៉ាងច្រើនដោយប្រើគំនិតប្រាជ្ញា។ តើយើងត្រូវការពិន្ទុប៉ុន្មានទៀតដើម្បីឈ្នះ តើត្រូវឲ្យមានការខិតខំប៉ុន្មានដងទៀតទើបយើងអាចឈ្នះ ហើយថាតើយើងមានពេលគ្រប់គ្រាន់ឬទេ?

ការធ្វើដំណើរ ការចែករំលែកគ្នាបង់វិក្កយបត្រ ការទៅផ្សារ ការលេង ឬការមើលកីឡា និងការរៀបចំចំណីអាហារ ទាំងនេះទាក់ទិននឹងការគិតលេខដោយប្រើគំនិតប្រាជ្ញា។ របៀបដែលយើងប្រើ ពេលណាយើងគិតលេខដោយប្រើគំនិតប្រាជ្ញារបស់យើង ជាញឹកញយពុំមានរបៀបដូចគ្នានឹងរបៀបដែលយើងប្រើនោះឡើយ ពេលណាយើងសរសេរចម្លើយសារុប។

ដំណើរទាក់ទិននឹងការគិតលេខដោយប្រើគំនិតប្រាជ្ញានៅតែជារឿងអាថ៌កំបាំងមួយ ក្នុងចំពោះកុមារជាច្រើន ហើយទោះបីជាមនុស្សជំទង់ក៏ដូចគ្នាដែរ។ ការគិតលេខ 998 x 3 គឺជាកិច្ចការលំបាកមួយ ទោះបីជាប្រើប៊ិច ឬក្រដាសក្តី ប្រសិនបើលោកអ្នកមិនដឹងថាលោកអ្នកអាចគិតឃើញចម្លើយដូចគ្នាដោយប្រើគំនិតប្រាជ្ញាដោយដកលេខ 6 ចេញពីលេខ 3000 ឡើយ។

## ដូច្នេះ តើកុមាររៀនចេះគិតលេខដោយប្រើខួរក្បាលដោយបែបណា?

កុមារចាប់ផ្តើមដំបូង ដោយរាប់វត្ថុដែលគេអាចមើលឃើញ ហើយប្រើវត្ថុទាំងឡាយដើម្បីបូក និងដក។ តាមរយៈការហាត់ធ្វើនោះ កុមារនឹងចាប់ផ្តើមចេះគិតពីរបៀបបូក និងដកដោយពុំចាំបាច់ប្រើវត្ថុ។ វិធីដំបូងមួយក្នុងចំណោមវិធីដំបូងឯទៀត ដែលកុមាររៀនចេះបូកលេខចំនួនពីរដោយប្រើគំនិតប្រាជ្ញា គឺចាប់ផ្តើមជាមួយលេខធំ ហើយចាប់រាប់បន្តម្តងមួយៗដើម្បីបូកទៅនឹងលេខទីពីរ។ នេះគឺជាវិធីមួយដ៏មានប្រសិទ្ធិភាពពេលណាបូកបន្ថែមជាមួយលេខតូច។ កាលណាកុមារចាប់ផ្តើមរៀនដោះស្រាយជាមួយលេខធំ នុះគេចាប់ផ្តើមបង្កើតនូវវិធីធំទូលាយផ្សេងទៀត ក្រៅពីការរាប់លេខមួយម្តងៗ។

ឧទាហរណ៍ ដើម្បីរកចម្លើយ 25 + 89 កុមារអាចៈ

- ប្តូរ 89 ឲ្យទៅជា 90 បន្ទាប់មកបូកបន្ថែម 10 រួចមក 14
- បូក 20 ជាមួយ 80 ឲ្យទៅជា 100 បន្ទាប់មកបូក 9 ជាមួយ 5 បន្ទាប់មកបូក 100 ជាមួយ 14
- បូក 10 ពីរដងទៅលេខ 89 រួចមកបូកបន្ថែម 5។

មានកិច្ចការមួយដែលគួរឲ្យចាប់អារម្មណ៍អំពីការគិតលេខដោយប្រើគំនិតប្រាជ្ញា គឺថាយើងគ្រប់គ្នាមិនគិតដូចគ្នាឡើយ។

NEW SOUTH WALES
DEPARTMENT OF EDUCATION AND TRAINING

© State of New South Wales through the NSW Department of Education and Training, 2007.

# តើលោកអ្នកអាចធ្វើអ្វីបានខ្លះនៅផ្ទះ?

- សួរកូនរបស់លោកអ្នកថាតើគេគិតឃើញចម្លើយបែបណាដោយប្រើគំនិតប្រាជ្ញា។ ពន្យល់ប្រាប់គេពីរបៀបដែលលោកអ្នកគិតឃើញចម្លើយដោយប្រើគំនិតប្រាជ្ញា។ ប្រសិនបើកូនរបស់លោកអ្នកមិនអាចគិតឃើញចម្លើយដោយប្រើគំនិតប្រាជ្ញាទេ ចូរឲ្យវត្ថុទៅគេដើម្បីរាប់។
- ឲ្យកូនរបស់លោកអ្នកគិតចំនួនលុយអាប់ដែលគេនឹងបានមកវិញ ពេលណាបង់ថ្លៃវត្ថុដែលទិញពីផ្សារ។
- ប្រសិនបើកូនរបស់លោកអ្នកសន្សំលុយដើម្បីទិញរបស់មួយ សួរគេថាតើគេត្រូវការសន្សំលុយប៉ុន្មានទៀតដើម្បីទិញឲ្យបានរបស់នោះ។
- លើកទឹកចិត្តកូនរបស់លោកអ្នកឲ្យចេះប៉ាន់ស្មានតម្លៃវត្ថុពីរមុខ នៅពេលទៅផ្សារ។
- ពេលណាលេងល្បែងកំសាន្តដែលប្រើដុំឡុកឡាក់ ចូរប្រើដុំដែលមានលេខ ជាជាងដុំដែលមានតែសញ្ញាចុចៗ។
- ប្រសិនបើមើលកីឡាទាក់ទិននឹងអ្នកលេងពីរក្រុម ឲ្យកូនរបស់លោកអ្នកគិតដោយប្រើគំនិតប្រាជ្ញាអំពីពិន្ទុខុសគ្នារវាងក្រុមទាំងពីរនោះ។
- ឲ្យកូនរបស់លោកអ្នកទាក់ទិនក្នុងការគិតតម្លៃទាក់ទិននឹងដំណើរកំសាន្ត។ ឧទាហរណ៍ *យើងនឹងស្នាក់នៅចំនួន៥ថ្ងៃដែលមានតម្លៃ $70 ក្នុង១ថ្ងៃ។*



NEW SOUTH WALES DEPARTMENT OF EDUCATION AND TRAINING

© State of New South Wales through the NSW Department of Education and Training, 2007.